# សៀវភៅគតិលោក
## ភាគ ទី៩



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.COM
ចេវ បន្ទុរណៈ

# រឿងសត្វស្កាពីរបែកផ្លូវគ្នារកចំណី

## និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានសត្វស្កាពីរ ស្កាមួយទទួលស៊ីតែសត្វជើងបួនស្កាមួយទទួលស៊ីតែសត្វស្លាប ៗ ឯស្កាស៊ីសត្វស្លាបដើរស្វែងរកអាហារ បានឃើញសត្វប្រចៀវមួយទំសំយុងខ្លួននៅរអាងថ្មភ្នំ ក៏ស្ទុះទៅចាប់ប្រចៀវនោះបាន ហើយពោលថាអញរតតែសត្វស្លាបនិងស៊ី ឥឡូវបានសត្វស្លាបសមក្ដីប្រាថ្នាអញហើយ ៗ ប្រចៀវបានឮស្កាថាដូច្នោះក៏ពោលឡើងថា "ខ្ញុំនេះនឹងបានជាពួកសត្វស្លាប ជាអណ្ឌជះកំណើតកើតដោយស៊ុតក៏ទេ ខ្ញុំនេះជាពួកកណ្ដុរសត្វជើងបួន ជាជលម្ពុជ កំណើតទេតើបើអ្នកមិនជឿខ្ញុំអញ្ជើញមើលមុខខ្ញុំចុះ មុខខ្ញុំជាកណ្ដុរ មានស្លឹកត្រចៀកទាំងពីរដូចកណ្ដុរ ៗ នោះឯងដែលខ្ញុំហើរបាននោះគឺហើរដោយស្បែក និងបានជាសត្វស្លាបមានរោមដូចបក្សីកាលណា" ៗ ស្កាឮដូច្នោះក៏គន់មើលមុខប្រចៀវយល់ដូចមុខកណ្ដុរមែន ទើបថាអញនេះខុសសញ្ញាខ្លួនហើយ ថាហើយក៏លែងប្រចៀវឲ្យហើរទៅ អាត្មាឯងក៏ទៅស្វែងរកអាហារនាទីឯទៀតហោង ៗ

ប្រចៀវនោះបានរួចពីមាត់ស្កាហើយក៏ហើរទៅទំសំយុងក



ចុះនៅជ្រុងថ្មមួយ ៗ ក្នុងថ្ងៃនោះស្កាដែលប្រកាន់ស៊ីសត្វជើងបួនដើរស្វែងរកអាហារ លុះមកដល់ទីជ្រុងថ្មបានឃើញប្រចៀវនោះ ក៏ស្ទុះលោតទៅចាប់បាន ហើយពោលថាអញរកតែសត្វកណ្ដុរជាតិសត្វជើងបួន ឥឡូវបានវាសមក្ដីប្រាថ្នាហើយអញនឹងស៊ីវាឥឡូវនេះ ៗ ប្រចៀវឆ្លើយថា "ខ្ញុំនេះនឹងបានជាកណ្ដុរពួកសត្វជើងបួនកាលណា ខ្ញុំជាសត្វបក្សាជើងពីរទេ ចូរអ្នកមើលស្លាបមើលជើងខ្ញុំចុះ បើអ្នកមិនជឿអ្នកលែងខ្ញុំឲ្យហើរមើលទៅ" ៗ ស្កាក៏គន់មើលឃើញស្លាបឃើញជើងពីរ ដូចពាក្យប្រចៀវពោលមែន ទើបលែងប្រចៀវនោះបង់ ហើយក៏ចេញទៅរកអាហារក្នុងទីទៀតហោង ៗ

រឿងនេះ បានគតិដល់បុគ្គលអ្នកគេចកែប្រែក្នុងកាលគេឃោសនាយកអ្វីៗដូចយ៉ាងចៅជ្វាម្នាក់តាំងលំនៅក្នុងភូមិខ្មែរ ថ្ងៃមួយមានរាជការឲ្យកេណ្ឌយកពួកជ្វាទៅចែវទូកប្រណាំង ចៅនោះគេចកែថាខ្ញុំបាននេះជាខ្មែរទេ បើលោកមិនជឿអញ្ជើញមើលរូបខ្ញុំបាទចុះ ខ្ញុំបាទនឹងបានកោរក្បាលពាក់កន្ទបស្លៀកសារុងកាលណា ខ្ញុំបាទស្លៀកពាក់ជាខ្មែរ ដូចខ្មែរទាំងឡាយក្នុងស្រុកនេះដែរ ៗ នាយកំណែនឮដូច្នោះក៏លែងកេណ្ឌចៅនោះ

នោះក៏រួចខ្លួនហោង ៗ លុះនៅយូរមករាជការឲ្យកេណ្ឌយកខ្មែរបររទេះជូនអាជ្ញាហ្លួង គេទៅកេណ្ឌចៅនោះៗគេចកែប្រែថាខ្ញុំបាទនេះជាជាតិជ្វាចាមទេ នឹងបានជាខ្មែរកាលណា បើលោកមិនជឿខ្ញុំបាទក្រែងខ្ញុំបាទកុហក់ខ្ញុំបាទហ៊ានបង្ហាញរបស់កំបាំងក្នុងខ្លួន ជូនលោកមើលជាសាក្សី ៗ នាយកំណែនឮដូច្នោះក៏លែងកេណ្ឌចៅនោះៗ រួចកំណែនបរទេះនោះហោង ៗ

លុះដល់ពួកតុកទួនជ្វាគេឃោសនា បណ្ដាជ្វាដូចគ្នាយកប្រាក់សាងសាវ៉ាទ់ ចៅនោះគេចកែថាខ្លួនខ្មែរទេនឹងចេញប្រាក់ធ្វើបុណ្យជ្វាដូចម្ដេចបាន បើសាសន៍ខុសគ្នាយ៉ាងនេះ លុះនៅយូរមកមានពួកសប្បុរសខ្មែរគេទៅឃោសនាចៅនោះ ឲ្យចេញប្រាក់សាងវិហារចៅនោះក៏គេចកែប្រែថាខ្លួនជ្វាទេ នឹងចេញប្រាក់ធ្វើបុណ្យដូចម្ដេចបាន បើសាសន៍ខុសគ្នាយ៉ាងនេះ ៗ មនុស្សគេចកែប្រែប្រកបទៅតាមពួក ចូលទៅក្នុងសំណាក់ពួកណា ក៏ឆ្លើយថាខ្លួនជាពួកនោះដែរប្រចុបប្រចែងតែងកលយកលាភក្នុងពួកនោះៗ យ៉ាងនេះក៏មាន អញ្ជើញប្រាជ្ញគិតតទៅទៀតចុះ ៗ

ប្រអើយប្រចៀវ ចេះគេចចេះកៀវ ចេះកែប្រែជាតិ



ចោទថាបក្សា ឆ្លើយថាចតុប្បាទ បំណងស្កាខាត ខានបរិកោក្កា ៗ ក្រោយចោទចតុប្បាទ កែប្រែថាជាតិ សកុណបក្សា ស្កាស្កុនខានស៊ី ខុសទីសញ្ញា ផ្លូវពីរយាត្រា តាមតែនឹងត្រាប់ ៗ

**ចប់តម្រាគេចខ្លួន ជាគតិទី ៥៣។**

## រឿងសត្វត្រចៀកកាំនឹងគ្រាប់ធ្មៃ

**និទាននេះ មានដំណាលក្នុងក្បួនបារាំងសែស**

មានសត្វត្រចៀកកាំមួយ ហើរទៅឃើញអ្នកចំការម្នាក់ព្រួសគ្រាប់ធ្មៃ គ្រាប់ក្រចៅនៅទីមួយក៏គិតឃើញថា គ្រាប់ពូជនេះកើតឡើងជាសត្រូវដល់ពួកសកុណបក្សីនានា លុះគិតដូច្នោះហើយ ក៏ហើរទៅប្រាប់បក្សីចាបទាំងឡាយថា "ម្នាលចាបទាំងឡាយអ្នកឯងរាល់គ្នា បានឃើញសត្រូវរបស់ខ្លួនហើយឬ? ចាបទាំងឡាយបានឮហើយក៏សួរថា "សត្រូវរបស់យើងនោះនៅឯណាហះ? ៗ ត្រចៀកកាំប្រាប់ថា "អ្នកទាំងឡាយបានឃើញមនុស្សម្នាក់ គេព្រួសគ្រាប់ធ្មៃគ្រាប់ក្រចៅឬទេ? គ្រាប់ពូជនោះហើយ ជាសត្រូវដល់អ្នកទាំងពួង នែអ្នកទាំងឡាយឯគ្រាប់ពូជនោះតែដុះធំឡើងកាលណា គេកាប់យកទៅកូតថ្កូតធ្វើជាសំណាញ់ផាលប់ ដាក់យកពួកចាបទាំងឡាយទៅប្រហារបរិ..

ភោគតាមក្ដីប្រាថ្នា ហេតុនោះបានជាយើងពោលថាគ្រាប់ពូជនោះ ជាសត្រូវរបស់ចាបព្រាបទាំងឡាយនឹងកើតមានទៅខាងមុខ, អើបើអ្នកទាំងឡាយចង់បានក្ដីសុខទៅខាងមុខ គួរតែនាំគ្នាចុះទៅស៊ីគ្រាប់ពូជនោះ ឬជួយចឹកពាំនាំគ្រាប់ពូជនោះទៅចោលឯទីមានស្មៅឲ្យអស់ កុំឲ្យពូជនេះដុះឡើងបាន បើបណ្ដោយឲ្យកើតហើយ ក្ដីអន្តរាយចំពោះនឹងមានដល់អ្នកទាំងឡាយទៅមុខមិនខានឡើយ"ៗ ឯហ្វូងចាបនោះ ទុកជាបានឮពាក្យត្រចៀកកាំប្រាប់ដូច្នោះ ក៏ពុំមានអើពើធ្វើតាមឡើយ នាំគ្នាព្រងើយកន្តើយដោយភាពកំជិល ភាពសប្បាយមិនយល់ក្ដីទុក្ខទៅខាងមុខនឹងបៀតបៀនខ្លួនឡើយ លុះនៅយូរមកក្រចៅផ្ទៃនោះ ដុះចំរើនធំឡើងដល់ចាស់កំណត់ពេញការ ចៅម្ចាស់ចំការ ក៏កាប់យកទៅកូតថ្កូតជាខ្សែ ហើយចងជាសំណាញ់ បានជាលប់យកទៅដាក់ចាបនៅទីវាលមួយៗ ចាបទាំងឡាយមិនស្គាល់ជាលប់បានឃើញស្រូវដែលគេបាចសាចជានុយ ក៏នាំគ្នាចុះស៊ី នាយលប់ក៏ទាញលប់វាត់ត្រសោបរួបយកចាបទាំងហ្វូងនោះបាន ហើយចាប់ដាក់ទ្រុង យកទៅលក់ទៅប្រហារស៊ីហោងៗ



ឯចាបទាំងឡាយ កាលត្រូវលប់ត្រូវទ្រុងគេហើយ ទើបនាំគ្នាគិតដល់ឱវាទ នៃសត្វត្រចៀកកាំដែលបាននិយាយប្រាប់ឲ្យគិតបំផ្លាញគ្រាប់ផ្ទៃ គ្រាប់ក្រចៅ កុំឲ្យដុះបាន ហើយខ្លួនពុំនាំពាអើពើធ្វើតាមទៅប្រមាទគ្រាប់ផ្ទៃ គ្រាប់ក្រចៅថាមិនអាចចងព័ទ្ធខ្លួនបានទេ ឥឡូវនេះត្រូវដូចពាក្យត្រចៀកកាំនោះហើយ, ឱយើងអើយផុតផ្លូវកែខែដល់នូវអាយុខ័យក្ស័យវិនាសពិតហើយ ទោសនេះនឹងបន្ទោសនរណាគឺបន្ទោសខ្លួនឯងមិនតាមឱវាទត្រចៀកកាំ ដែលពោលប្រាប់ពោលប្រើនោះឯងៗ ចាបទាំងឡាយសោកស្ដាយគំនិតស្ដាយជីវិតពន់ពេក នាំគ្នាស្រែទ្រាំតាមយថាកម្មហោងៗ

រឿងនេះ បានគតិដល់បុគ្គលអ្នកមិនយល់ក្ដីអន្តរាយនឹងមកដល់ខ្លួន ទោះមានគេប្រាប់ ក៏មិនជឿស្ដាប់ មិនប្រព្រឹត្តទៅតាមបានក្ដីប្រមាទថានៅឆ្ងាយ នៅតូច មិនដល់ខ្លួនទេ ដូចយ៉ាងពិសកាលកើតនៅតូចមិនទាន់ចេញកំឡាំងនោះគិតខ្វល់ខ្វាយរកពេទ្យឬគ្រូថ្នាំឲ្យមើល ឲ្យរក្សាខ្លួនទេប្រមាទនៅទាល់តែរោគពិសនោះ កើតកាយផ្សាយពិសពេញកំឡាំង បាននូវក្ដីទុក្ខវេទនា ជាសហ័សមួយទៀត ដូចបុគ្គលពាលធ្វើនូវអំពើបាបកម្ម

បើបាបនោះនៅមិនទាន់ឲ្យផល ក៏សំគាល់ថាបាបនោះផ្អែមដូចទឹកឃ្មុំ លុះបាបបោះឲ្យផលដល់កាលណាទើបស្រែកទួញយំរងទុក្ខក្នុងកាលនោះ ៗ

បទនេះរួមដោយពាក្យបាលីក្នុងលោកនីតិថា៖

មធុវ មញ្ញតិ ពាលោ
យាវ បាបំ ន បច្ចតិ
យទា ច បច្ចតិ បាបំ
ថេ ទុក្ខំ និគច្ឆតិ។

ប្រែថា បាបពុំទាន់ឲ្យផលដល់កាលណាពាលគិតថាបាបនោះដូចទឹកឃ្មុំលុះបាបកម្មឲ្យផលដល់ប្រជុំ ទើបពាលរងទុក្ខធំក្នុងកាលនោះ ៗ

**ចប់តម្រាប្រមាទសត្រូវនៅតិចតួចឆ្ងាយ ជាគតិទី ៥៤។**

## រឿងព្រានសន្ទូចម្នាក់

មានព្រានសន្ទូចម្នាក់ ថ្ងៃមួយនាំកូនទៅស្ទូចត្រីនៅទីស្ទឹងមួយ លុះស្ទូចទៅសន្ទូចនោះធ្លាក់ទៅព័ទ្ធជាប់នឹងដង្កត់ឈើក្នុងទឹក ចៅព្រានវាត់ឡើងសំគាល់ថាត្រូវត្រីហើយ លុះវាត់ទាញមិនរួចក៏នឹកថាត្រូវត្រីធំ ទើបប្រាប់ចៅកូនថាយើងមានលោភបានត្រីធំ



ហើយនឹងលើកយកពុំរួច មានតែអញចុះទៅមុជចាប់យកទើបបាន បើដូច្នេះ កូនឯងទៅប្រាប់ម៉ែឯងឯផ្ទះឲ្យដឹងថាយើងបានត្រីធំណាស់ ឲ្យម៉ែងដើរបង្កហេតុជំលោះនឹងពួកញាតិ នឹងពួកព្រៀងលានដែលនៅជិតខាង ឲ្យកើតទាស់ទែងគ្នាឡើងជាការកាល់ហាមពួកអស់នោះ កុំឲ្យមកសុំត្រីយើងបាន ឯចៅកូនទទួលពាក្យហើយ រត់ត្រង់ទៅផ្ទះ ដល់ហើយក៏ថ្លែងសេចក្ដីនុ៎ះប្រាប់ម្ដាយ តាមពាក្យឪពួកបង្គាប់មកនោះសព្វប្រការ ឯនាងភរិយាចៅព្រាន បានស្ដាប់ហេតុដូច្នោះហើយ ក៏ដោះអាវចេញពីខ្លួនយកក្រមាមកចោមពុងស្លៀកសំពត់សំយេះក្រោមនាភី លាតសំពត់លើជង្គង់បកធ្យូងឆ្នាំងសំឡលាបមុខ ធ្វើអាការដូចស្រីឆ្កួតហើយដើរទៅកាន់ផ្ទះពួកញាតិសន្ដានព្រៀងលានដែលនៅជិតខាង ៗ

ឯបណ្ដាប្រុសស្រីជាញាតិ បានឃើញអាការកិរិយាប្លែកដូច្នោះយកនាំគ្នាសួរថា ហងអើយហងម្ដេចហងមកធ្វើអំពើអាក្រក់ យកធ្យូងឆ្នាំងមកលាបមុខដូច្នេះ"ៗ ឯមេនោះនិមិត្តតែញាតិណាសួរដូច្នេះក៏ស្រែកជេរបញ្ជោរទៅថា ខ្មោចមេចោរអាចោរអស់នេះ ចុះវាធ្លន់ក្បាលអ្វីវា ថ្វីបើអញលាបធ្យូងតើ

អញ្ញទៅធ្វើអ្វីវា ល្អអាក្រក់តើវាទើសក្បាលម្ដាយអាពុកវាឬ ខ្មោចមេបោរ អាចោរអស់នេះពេញ្ញជាខូច ៗ ឯពួកញ្ញាតិទាំងឡាយ បានឮមេនោះជេរប្រទេចផ្ដាសាឥតហេតុដូច្នោះ អ្នកខ្លះអត់មិនបានក៏ជេរតបទៅ កើតជាអធិករណ៍ឈ្លោះប្រកែកឡើង អ្នកខ្លះខឹងក៏ធ្វើរឿងវ៉ាទប្ដឹងដល់សាលាចៅក្រមៗ ឲ្យកោះបកតួនាងនោះមកជំនុំជំរះតាមរឿងចោទ រកទៅឃើញទោសខាងនោះជាអ្នកដើរបង្កហេតុ ទើបចៅក្រមសាលាកាត់ពិន័យលក់តាមសក្តិតូចសក្តិធំ តាមទោសដែលខ្លួនជេរគេឥតទោសនោះឯង ៗ ថ្លែងឯចៅព្រានជាប្ដី កាលប្រើកូនឲ្យទៅប្រាប់ម្ដាយវានោះ ក្រោយនោះចៅព្រានស្រាតសំពត់ដាក់នៅលើប្រាំង ហើយមុជចុះទៅតាមខ្សែសន្ទូចដើម្បីនឹងចាប់ត្រី លុះមុជទៅដល់ដង្គត់ឈើក្រោម ឈើនោះប៉ះមកត្រូវភ្នែកដូចជាគេចាក់ចុងកន្ទុយភ្នែក ខំស្ទាបរកត្រីមិនឃើញមានតែឫសឈើជាប់សន្ទូច ទើបខំងើបឡើងវិញ យកដៃខ្ទប់មុខវាយឈើភ្នែកមហិមា ខំវារឡើងដើម្បីនឹងយកសំពត់ស្លៀក ៗ ឯសំពត់នោះសោត កាលចៅព្រានមុជទឹកទៅ ត្រូវខ្យល់កំបុតត្បូងកួចទម្លាក់ទៅក្នុងទឹកទឹកក៏កួចយកសំពត់នោះអន្ដរធានទៅហោង ៗ



ចៅព្រានបានក្ដីវេទនាដោយរងា ដោយឈឺភ្នែកនឹងទៅផ្ទះក៏ពុំបាន ព្រោះប្រាណអាត្រាតខ្មាស់អ្នកស្រុក នឹងទ្រាំនៅត្រាំក្នុងទឹករងាណាស់ ទើបព្រានឡើងទៅលាក់ខ្លួនពួននៅក្នុងព្រៃទំរាំអស់សែងថ្ងៃនៅរង់ដល់ពេលយប់ទើបបានទៅផ្ទះ ទៅដល់ផ្ទះហើយក៏ពុំហ៊ានឡើងផ្ទះ ដោយនាងប្រពន្ធអុជភ្លើងភ្លឺស្រែកហៅប្រពន្ធ ឲ្យបោះសំពត់មួយមកស្លៀក ទើបឡើងទៅបានហើយក៏និយាយពីក្ដីទុក្ខវិនាសទ្រព្យដោយគេលក់ព្នែ ប្រាប់គ្នាទៅមកតាមរឿងដែលខ្លួនធ្វើខុសនោះឯង ជនទាំងពីរក៏បានក្ដីវិនាសផ្លូវទាំងពីរប្រការ គឺផ្លូវព្រៃក៏ពុំបានត្រី សំពត់ស្លៀកក៏អន្តរធានដោយខ្យល់កួចយកទៅ ភ្នែកក៏បែកដោយត្រូវនឹងដង្គត់ឈើនោះ ឯផ្លូវផ្ទះក៏វិនាសដោយពួកញ្ញាតិគេខឹងគេប្ដឹងបង់ទ្រព្យធន ដោយចាញ់ក្ដីគេផងម៉្លោះហើយក៏នាំគ្នាសោកសៅក្ដៅចិត្ត ដោយគំនិតគិតខុសនោះហោង ៗ

រឿងនេះ បានគតិដល់បុគ្គលកំណាញ់លាភភ័យក្រែងគេមកសុំត្រីខ្លួន ប្រាជ្ញគប្បីប្រកបគតិទៅទៀតចុះ ៗ

ព្រានអើយព្រានព្រាហ្មណ៍ សន្ទូចជាប់វាមព្រាហ្មណ៍ថាត្រីធំ កើតចិត្តហួងហែង ភ័យក្រែងគេសុំ បង្កហេតុជំ លោះឡើងគ្រប់

ឋាន ។ កើតកាឡកិណី ផ្លូវផ្ទះកើតក្ដី បាញ់បង់ធនធាន ផ្លូវព្រៃខ្យល់ផាត់ សំពតពីប្រាណ ត្រីសោតពុំបាន សាផ្នែកបែកអើយ ។

**ចប់ តម្រាហ្លួងលាភដែលពុំទាន់ឃើញ ជាគតិទី ៥៥។**

## រឿងអទិន្នបុព្វកព្រាហ្មណ៍

មានព្រាហ្មណ៍ម្នាក់ឈ្មោះអទិន្នបុព្វកព្រាហ្មណ៍នៅក្នុងនគរសាវត្ថី បានជាឈ្មោះថា អទិន្នបុព្វកនោះដោយអត្ថថាព្រាហ្មណ៍នោះជាមនុស្សកំណាញ់កាញ់សម្បត្តិទុក្ខ មិនដែលបរិច្ចាគទ្រព្យចេញធ្វើបុណ្យឲ្យទានដល់សមណព្រាហ្មណ៍ និងស្មូមយាចកទាំងឡាយឡើយ ព្រាហ្មណ៍នោះមានកូនប្រុសម្នាក់ឈ្មោះមដ្ឋកុណ្ឌលី បានជាឈ្មោះថាមដ្ឋបុណ្ឌលីនោះ ព្រោះកូននោះចំរើនធំហើយ អទិន្នបុព្វកព្រាហ្មណ៍ជាបិតា ប្រារព្វនឹងធ្វើកុណ្ឌល ជាគ្រឿងបំពាក់ឲ្យគិតថានឹងទៅជួលជាងទងធ្វើ ក្រែងបង់ថ្លៃឈ្នួល ទើបព្រាហ្មណ៍យកមាសមកដំដោយខ្លួនឯង ធ្វើជាកុណ្ឌលមានភាពរលីងឥតក្បាច់ ហើយបំពាក់កូននោះ ហេតុដូច្នោះ ទើបកូននោះបាននាមថា មដ្ឋកុណ្ឌលីកុមារ (ថាចៅកុណ្ឌលរលីង)លុះចណេរតមកចៅមដ្ឋកុណ្ឌលីនោះមានជម្ងឺឈឺ គឺរោគស្គមលឿង ទើបនាងព្រាហ្មណីនិយាយនឹងប្ដីថា "អ្នកអើយ! កូនយើងកើត



រោគស្គមលឿងឈឺរឹងរៃយ៉ាងនេះ គួរអ្នកទៅរកគ្រូពេទ្យមកមើលមករក្សា នឹងបណ្ដោយឲ្យជាឯងនោះឃើញថាមិនជាទេអ្នក ។ ឯចៅព្រាហ្មណ៍ជាអ្នកខ្លាចបង់ខាតសម្បត្តិ គិតថាបើអញទៅរកគ្រូឲ្យមករក្សាកូននេះហើយ នឹងបង់ទ្រព្យដោយតំនាប់គេផងដោយអាហារចំណីល្បៀងគេនោះផង ទ្រព្យអញនឹងខាតទៅ ព្រាហ្មណ៍គិតដូច្នោះហើយ ក៏ធ្វើព្រងើយកន្តើយមិនអើពើ ក្នុងការរកគ្រូមករក្សាកូនឡើយលុះអាការរោគកូននោះ ប្រែខ្លាំងឡើង ព្រាហ្មណ៍ទាល់គំនិតទើបដើរត្រាប់ទៅតាមផ្ទះគ្រូពេទ្យ ហើយក៏ចូលសួរគ្រូពេទ្យថា "អើអ្នកគ្រូថ្នាំ តើគេកើតរោគលឿង អាការរោគនោះស៊ីពុំបាន ដេកពុំបាន នៅទីឯនោះដូច្នេះ តើគេប្រើថ្នាំយ៉ាងណាគេរក្សាដូចម្ដេច" ។

ឯគ្រូថ្នាំបានឮអទិន្នបុព្វកៈសួរដូច្នោះ ក៏ប្រាប់ផ្ដាសទៅថា យកឫសឈើនោះ យកស្លឹកនោះៗមកស្ងោរឲ្យផឹកទៅចុះ ពាក្យគ្រូប្រាប់ថ្នាំនោះគេយល់ថាព្រាហ្មណ៍កំណាញ់ទ្រព្យ មិនហ៊ានអញ្ជើញគេទៅឲ្យមើលកូន ក្រែងបង់ថ្លៃអាហារនឹងល្បៀងគេ ទើបគេប្រាប់ផ្ដេសផ្ដាសទៅ ។ ឯអទិន្នបុព្វកព្រាហ្មណ៍ឮគេប្រាប់ដូច្នោះ ក៏មករកជីកឫសឈើ បេះស្លឹកឈើទៅធ្វើ

ថ្នាំតាមគេបង្គាប់នោះ ឯរោគកូននោះពុំអាចនឹងរងាប់ដោយថ្នាំផ្តេសផ្តាសនោះឡើយ រឹងរឹតតែឈឺធ្ងន់ឡើង ចៅព្រាហ្មណ៍យល់អាការរោគកូនកាន់តែធ្ងន់ដល់នូវក្តីទុព្វលភាពខ្លាំង ដឹងថារោគនោះមើលមិនជាហើយ ទើបគិតថាកូនអញឈឺធ្ងន់ហើយនឹងទុកឲ្យនៅក្នុងផ្ទះនេះយល់ជាពុំបាន ក្រែងពួកញាតិមិត្រទាំងឡាយ គេចូលមកសួរជម្ងឺ គេនឹងឃើញទ្រព្យសម្បត្តិអញហើយ គេនឹងមកកួនខ្ចី ឬសុំអញតទៅមុខទៀតបើដូច្នេះ មានតែលើកវាទៅដាក់ឲ្យដេកឰដ៏ល្វែងតាកខាងក្រៅទើបផុតក្តីរំខាន គិតហើយ អទិន្នបុព្វកព្រាហ្មណ៍នឹងប្រពន្ធ នាំគ្នាសែងគ្រែកូនចេញមកដាក់ឲ្យដេកនៅល្វែងតាកផ្ទះ ឯចៅមដ្ឋកុណ្ឌលីកុមារនោះលុះរោគកម្រើកខ្លាំងហើយ ក៏ដល់នូវកាលកិរិយាក្ស័យឰដ៏កាលនោះហោង ។

ឯជនទាំងពីរយល់កូនក្ស័យហើយ ក៏គក់ទ្រូងទួញយំសោកស្តាយដោយក្តីសង្សារស្នេហាអាល័យបុត្រ នាំគ្នាយកសពបុត្រទៅដុតនៅព្រៃប៉ាឆាតាមប្រពៃណីព្រាហ្មណ៍ ។ អទិន្នបុព្វកព្រាហ្មណ៍ដើមពីថ្ងៃនោះមកពុំសប្បាយឡើយ តែងទៅទួញយំសោកនៅទីប៉ាឆានោះ រាល់ៗពេលដោយក្តីបុត្តវិយោគជាសរលាបថ្នាំ



ពិស មុតជាប់ខ្លួនហោង ។

រឿងនិទាននេះ មានសេចក្តីពិស្តារនៅក្នុងគម្ពីរព្រធម្មបទបឋមភាគឯនោះ អញ្ជើញទៅមើលចុះក្នុងតំរាគតិលោកនេះ ខ្ញុំបាននាំយកមកសំដែងដោយសង្ខេប គ្រាន់ឲ្យឃើញជាបែបបុគ្គលអ្នកកំណាញ់ស្រឡាញ់តែសម្បត្តិទុក មិនហ៊ានចាយ ក្តីអន្តរាយដល់កូនដល់ខ្លួនហើយ ក៏នៅតែហួងហែង មិនចែកបែងបិទបាំងការពារអន្តរាយនោះឡើយ បុគ្គលយ៉ាងនេះ ហៅកំណាញ់ក្រៅតំរា មានទ្រព្យអសារឥតការ ឥតប្រយោជន៍ ដូចអ្នកខ្លះមានទ្រព្យរាប់ដល់រយពាន់ហ៊ឺនសែន ទុកណែនពេញទូដែកមិនហ៊ានចែកចាយចំណាយធ្វើបុណ្យឲ្យទាន ឬនឹងចេញប្រកបការ ឬក្នុងកាលត្រូវការបរិភោគខ្លួនឯង យ៉ាងនេះទ្រព្យនោះទុកស្មើដំឥដ្ឋថ្មដដែល ហៅថាអ្នកក្រអ្នកតោកយ៉ាកវិញក៏បាន បុគ្គលមានទ្រព្យច្រើន មិនបានចំរើនប្រយោជន៍ដល់អ្នកដទៃឬអាស្រ័យខ្លួនឯង ទ្រព្យនោះឯងប្រៀបដូចទឹកសមុទ្រ ច្រើនផុតវិស័យ តែរសប្រៃមនុស្សផងអាស្រ័យផឹកស៊ីពុំបាន ពាក្យនេះសមដោយលំអានបោរាណាចារ្យលោក ពោលទុកក្នុងគម្ពីរលោកនីតិថា ៖

ធនំ អប្បម្បិ សាធុនំ
កុបេ ភរីវ និស្សយេ
ពហុមបិ អសាធុនំ
ន ច ភរីវ អណ្ណវេ

ប្រែថា ទ្រព្យរបស់សប្បុរសទោះតិចតួច បានជាប្រយោជន៏ជននានា ដូចទឹកអណ្តូងរសសាបថ្លាអស់មហាជនផងដឹងអាស្រ័យ ៗ ទ្រព្យនៃអសប្បុរសទោះមានច្រើន ពុំបានចំរើនអ្នកដទៃ ដូចទឹកសមុទ្រមានរសប្រៃ មនុស្សផងអាស្រ័យផឹកពុំបាន ៗ

**ចប់តំរាកំណាញ់ក្រៅតំរា ជាគតិទី ៥៦។**

## រឿងមនុស្សចង់ស្លាប់

**និទាននេះមានដំណាល ក្នុងក្បួនបារាំងសែស**

មានចៅបុរសម្នាក់មានរោគឈឺរឹងរៃស្គាំស្គមថមថយកំលាំង តាំងសោយទុក្ខវេទនា នឹងនិទ្រាក៏ពុំលក់នឹងស៊ីចុកក៏ពុំបាន រីតរំខានពន់ពេក ស្រែកពោលថា ក្តីស្លាប់អើយកាលណានឹងដល់មកឆាប់ ៗ ស្លាប់ទៅប្រសើរជាងរស់នៅជាមនុស្សនេះ រស់នៅ



ថ្វីមិនត្រូវនឹងគេយ៉ាងនេះ ៗ ពាក្យចៅនោះហៅរកក្តីស្លាប់មកយកជីវិតខ្លួនរឿងៗ ឬមួយមានញាតិណាឡើងទៅសួរក៏ពោលទន្ទេញប្រាប់គេថា ចង់តែស្លាប់ឆាប់ៗទៅ មិនចង់រស់នៅជាមនុស្សឡើយ ៗ លុះយូរបន្តិចមក រោគនោះកាន់តែប្រែឈឺខ្លាំង ក៏តាំងស្រែកហៅថា លោកព្រះកាលអើយ ចូរមកកាច់កផ្តាច់ជីវិតខ្ញុំទៅក្នុងកាលឥឡូវនេះ ៗ

ឯក្តីស្លាប់ ក៏សំដែងជារូបចូលមក ឲ្យចៅនោះឃើញប្រចក្សចៅនោះកាលដើម ស្រែកហៅរកក្តីស្លាប់ នឹងចង់ស្លាប់ឆាប់ លុះឃើញក្តីស្លាប់ជិតដល់ មកក៏ភិតភ័យ ស្ទុះក្រោកស្រែករកឲ្យគេជួយ មិនចង់ស្លាប់ឡើយ តាំងបន់អង្វរក្តីស្លាប់ឲ្យចៀសចេញទៅវិញហោង ៗ

រឿងនេះ បានគតិដល់បុគ្គលទាំងឡាយក្នុងលោកិយនេះ សឹងចង់រស់នៅតែរាល់រូប ទោះរូបវិកលវិការ ខ្វាក់ខ្វិន គ ថ្លង់ ល្ងង់ល្ងើ ឬចាស់ជរា វារលូនទៅណាពុំរួចក្តី ក៏នៅតែអាល័យស្តាយជីវិត គិតចង់តែរស់នៅមិនចង់ស្លាប់ឡើយ ឯបុគ្គលមានក្តីទុក្ខវេទនាមកគ្របសង្កត់យ៉ាងខ្លាំង ហើយពោលថាចង់ស្លាប់នោះគឺពុំពិតទេ តែក្តីស្លាប់ដល់មកក៏ត្រឡប់ជាភិតភ័យប្រកែកមិន

ចង់ស្លាប់វិញ ប៉ុន្តែប្រកែកពុំបាននឹងអំណាចមច្ចុរាជនោះឯង ៗ ពាក្យពោលថាចង់ស្លាប់មិនពិតនោះ បានដូចនិទាននាងមេម៉ាយម្នាក់នាងនោះកាលប្តីស្លាប់ ក៏ទួញយំអាទ្បោះអាល័យប្តីថា "អ្នកប្រុសប្អូនអើយ អ្នកស្លាប់ទៅហើយមកយកប្អូនទៅផង", ពាក្យដែលនាងមេម៉ាយយំពណ៌នាយ៉ាងនេះកាលយំ នាងនោះ ឈរយំលើមាត់ប្រាំងៗនោះបាត់ក៏ធ្លាក់នាងមេម៉ាយ ដូចជាគេប្រមៀលរអិលទៅក្នុងព្រែក នាងនោះក៏ស្រែកថា "ប្អូនមិនទៅទេអ្នកបងអើយ ប្អូនមិនទៅទេ" ពាក្យនាងមេម៉ាយពោលមិនពិតដោយប្រការយ៉ាងនេះ ៗ ហេតុនោះ បានជាថាក្តីស្លាប់មួយនេះពុំមាននរណាថាចង់ស្លាប់សោះឡើយឯមនុស្សដែលសម្លាប់ខ្លួនឯង មានចងកជាដើមនោះនឹងបានស្លាប់ដោយចិត្តប្រក្រតីក៏ទេនឹងបានចង់ស្លាប់នោះក៏ទេសឹងខ្លាចក្តីស្លាប់ដូចគ្នាទាំងអស់ ឯអ្នកមិនខ្លាចក្តីស្លាប់នោះ មានតែអាជានេយ្យ៤ ពួកគឺ ដំរីអាជានេយ្យ១ សេះអាជានេយ្យ១ គោឧសភរាជ១ ព្រះខីណាស្រព១ត្រូវជា៤ ពួកអ្នក៤ពួកនេះតែដល់មាត់មច្ចុរាជហើយ ពុំតក់ស្លុតខ្លាចអំណាចក្តីស្លាប់នោះឡើយ តែក្រៅអំពីអាជានេយ្យ៤នោះហើយសឹងតក់ស្លុតខ្លាចអំណាចមច្ចុរាជ ដូចគ្នាទួទៅទាំងពិភព



គ្រប់តួសត្វមនុស្សហោង ៗ

ស្លាប់អើយក្តីស្លាប់ មិនស្លាប់បង្គាប់ អង្វរនរណា ទោះរាស្ត្រនោះស្តេច សំរេចលោកា ឬមានស៊ីសំណូក នរណាឲ្យលាភ ឬមានកំលាំង ច្បាំងឥតអានុភាព អាចកិនបានរាប រាល់រូបប្រុសស្រី ៗ ម្រឹតអើយម្រឹត្យូវ ជាតិជាសត្រូវ នៃយើងប្រក្រតី កើតហើយមានស្លាប់ សម្រាប់លោកិយ មានតែបុរី និព្វានមួយហោង ៗ

**ចប់តម្រាមិនយ៉មស្លាប់ជាគតិទី ៥៧។**

## រឿងសត្វទ្រោម នឹងសត្វសិង្ហតោ

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មានសត្វទ្រោមមួយ ហើរទៅឃើញសត្វសិង្ហតោមួយដេកនៅក្រោមដើមឈើ ក៏នឹកថាសត្វសិង្ហតោ មានអំណាចអង់អាចខ្លាំងណាស់ក្នុងលោកនេះគ្មានសត្វណាឈ្នះវាឡើយ បើដូច្នេះអញនឹងផ្ចាញ់វាក្នុងគ្រានេះ ទ្រោមនោះគិតហើយ ក៏ហើរទៅចុះទំខាំក្បាលសិង្ហតោៗ រលាស់គ្រវីក្បាល ទ្រោមក៏ចូលទៅក្នុងត្រចៀក សិង្ហតោក៏បោកបក់ចេញ ទ្រោមក៏ទៅទំទិចចុងច្រមុះសិង្ហតោគ្រវីបោកលោតត្របាក់ទ្រោមន ទ្រោមក៏ហើរគេចទៅទំខាងខ្នង ហើយហើរមករោមមុខទៀត សិង្ហតោ បានក្តី..

រំខាននឹងខាំក៏ពុំបាន នឹងដេកនៅក៏ពុំបាន ទើបក្រោកដើរចេញចាកទីនោះចូលទៅព្រៃទៅហោង។

ឯក្រមាមឃើញសិង្ហតោរត់ចេញចាកទីនោះ ក៏សំគាល់ថាខ្លួនមានជ័យជំនះ ឈ្នះសិង្ហតោហើយក៏ត្រេកអរទទឹកទាយសប្បាយចិត្តតាំងហើរទៅ ហើរមកស្រែកថា ឈ្នះហើយៗមាត់ស្រែកភ្នែកមិនបានជាមើល ក៏ប៉ះទៅលើមងពីងពាង ជាប់ដូចគេចងរុំខ្លួនជិត ខំកន្ត្រាងហើរក៏ពុំរួចឡើយ ពីងពាងដឹងថាក្រមាមជាប់មងខ្លួនហើយ ក៏ស្ទុះទៅខាំស៊ីជាចំណីហោង។

រឿងនេះ បានគតិដល់បុគ្គលពាលប្រទូសរ៉ាយអ្នកឥតទោស កម្មអកុសលនោះប្រែផ្លាក់មកលើខ្លួនឯងវិញ សមដោយពាក្យបុរាណថា"ធ្វើទុក្ខគេៗឲ្យទុក្ខវិញ" ប្រាជ្ញគប្បីពិចារណាទៅទៀតចុះ។

**ចប់តំរាឲ្យទុក្ខគេ ទុក្ខនោះបានមកលើខ្លួនវិញ ជាគតិទី ៥៨។**

## រឿងសត្វលលកនិងស្រមោចខ្មៅ

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មានសត្វលលកមួយ ហើរទៅបានឃើញពួកស្រមោចខ្មៅធ្លាក់នៅក្នុងទឹក ហែលតោងតែគ្នាឯងមានចិត្តអាណិតពួកស្រមោចនោះ ទើបទៅពាំយកមែកឈើដាប់១ មកដាក់ធ្វើជាស្ពានឲ្យស្រមោចអស់នោះតោងវាឡើងមកលើគោកបាន។

ស្រមោចទាំងឡាយ បានរួចពីក្តីស្លាប់ ដោយអំណាចឈើស្ពានដែលលលកដាក់ឲ្យខ្លួនតោងវារឡើងនោះឯង។

ថ្ងៃមួយ លលកហើរទៅទុំលើមែកជ្រៃ កាលនោះមានព្រានប្រមាញ់ម្នាក់ ដើរទៅឃើញលលកទុំលើមែកជ្រៃ ក៏ប្រាថ្នានឹងបាញ់លលកនោះ ឯស្រមោចទាំងឡាយ ដឹងថាព្រានប្រមាញ់ប៉ងនឹងបាញ់លលកដូច្នោះ ក៏នឹកដល់គុណលលកដែលបានធ្វើនឹងខ្លួន ទើបនាំគ្នាវារឡើងទៅខាំជើងនាយព្រាន ដើម្បីឲ្យនាយព្រាននោះ ភ្ញាក់កន្ត្រាក់ទន្ត្រាំជើងជាសូរឲ្យឮឡើងដល់លលកៗ នឹងបានដឹងខ្លួនហើយហើរទៅ។ នាយព្រាន កំពុងតែស្រងេងស្រែភ្នែកនឹងបាញ់ លុះស្រមោចឡើងរោមខាំក៏ធាក់ជើងឮសូរទើបៗ។

ឯលលកបានឮសូរសព្ទដូច្នោះហើយ ក៏បែរមើលទៅឃើញមនុស្សប៉ងនឹងឃាឃឺខ្លួន ទើបស្ទុះហើរចាកមែកជ្រៃនោះទៅកាន់ទីដទៃផុតក្តីស្លាប់ហោង។

រឿងនេះ បានគតិដល់បុគ្គលអ្នកធ្វើគុណៗ នោះអាចឲ្យក្តី

សុខវិញបាន ប្រាជ្ញគប្បីដឹងនិទានសត្វទ្រោមឲ្យទុក្ខដល់សត្វ សិង្ហតោ ក្ដីទុក្ខនោះបានមកលើសត្វទ្រោម គឺទៅត្រូវមងពីង ពាងវិនាសខ្លួនឯងវិញឯសត្វលលក ឲ្យក្ដីសុខដល់សត្វស្រមោចៗ ជួយឲ្យលលកផុតក្ដីទុក្ខ បានក្ដីសម្រាន្តវិញ ៗ

រឿងនិទានទាំងពីរនេះ បានដូចបទបាលីបុរាណតែងពោល ថា សុខតោ សុខថានំ ទុក្ខតោ ទុក្ខថានំ ដូច្នេះ ៗ

សុខអើយសុខា នៅរូបអ្នកណា អាចឲ្យសុខគេ គេនឹងបំពេញ សុខវិញមិនទេ អាចឲ្យទុក្ខគេ គេឲ្យទុក្ខស្នង ៗ នរណា ធ្វើគុណ គុណគង់ការុញ្ញ នាំសុខមកសង នរណាធ្វើទោស ទោសគង់អន្ទង់ នាំទុក្ខមកសង ឲ្យរងវេទនា ៗ

**ចប់គតិ ទី ៥៩។**

## រឿងសត្វបង្គួយនៅខ្លោងទ្វារព្រះបាទវិទេហរាស្ដ្រ

មានសត្វបង្គួយមួយ អាស្រ័យនៅលើខ្លោងទ្វារព្រះរាជវាំង នៃព្រះបាទវិទេហរាស្ដ្រ នៅក្នុងនគរមិថិលា បង្គួយនោះតែង បានឃើញស្ដេចយាងចេញចូលតាមទ្វារកាលណា ក៏ចុះមកដី ធ្វើសិរសីផ្ងក់ៗ គឺគំនាប់គោរពព្រះបរមរាជាតែរាល់ៗកាល ៗ ឯព្រះបាទវិទេមារាស្ដ្រ ស្ដេចយល់អាការកិរិយាបង្គួយនោះ..



ហើយក៏ត្រាស់សួរចៅមហោសថបណ្ឌិតពោធិសត្វៗ ក៏ក្រាប ទូលតាមហេតុបង្គួយឱនបង្គំចំពោះបរមរាជាទើបស្ដេចមានព្រះ ហឫទ័យត្រេអរ នឹងបង្គួយនោះឯង ហើយទ្រង់ប្រោសប្រាណ ព្រះរាជទានមាសមួយពិក្ដាមបើកឲ្យនាយពិសេស ទិញសាច់ ឲ្យបង្គួយអាស្រ័យតាមសម័យកាលអំពីថ្ងៃនោះមក ឯបង្គួយក៏ បាននៅសុខសប្បាយ ពុំបានខ្វល់ខ្វាយចេញទៅស្វែងរកអា ហារឯណាទៀយ ៗ

លុះនៅយូរមកមានកាលថ្ងៃមួយ នាយពិសេសរកទិញសាច់ ស្រស់មិនបាន ដោយជាថ្ងៃឧបោសថសិលពុំមានគេសម្លាប់សត្វ មួយទៀយ ទើបនាយពិសេសយកមាសមួយពិក្ដាមនោះមក ចោះដោតខ្សែហើយចងកបង្គួយនោះហោង ៗ

ឯបង្គួយនោះ តាំងពីបានមាសពាក់មកក៏កើតចិត្តស្រវឹងយស វាយកំពស់ក្អេងក្អាង កាលឃើញព្រះបាទវិទេហរាស្ដ្រស្ដេចយាង មកក៏គិតថា ស្ដេចនេះមានគ្រឿងអម្ពរដ៏ហើយដោយមាសពាក់ ប្រដាប់កាយឯអញសោត ក៏មានមាសពាក់ប្រដាក់កាយដូចគ្នា បើដូច្នេះ អញនឹងចុះទៅគំនាប់ស្ដេចនេះធ្វើអ្វីទៀត នាំឲ្យលំ បាក ការមានសក្ដិយសស្មើគ្នាយ៉ាងនេះ បង្គួយគិតដូច្នោះហើយ

ក៏ធ្វើព្រងើយកន្តើយពុំនាំពានឹងចុះមកវន្ទាដូចកាលមុនឡើយ ឯព្រះបាទវិទេហរាស្ត្រស្តេចយល់បង្គួយ មិនចុះពីខ្លោងទ្វារមកវន្ទាព្រះអង្គដូចថ្ងៃមុនៗដូច្នោះ ក៏ទ្រង់ព្រះពិរោធក្រោធខឹងបង្គួយនោះ ទើបត្រាស់ប្រើរាជអាមាត្យឲ្យធ្វើរងកទាក់បង្គួយនោះទំលាក់ចេញអំពីខ្លោងទ្វារ ហើយឲ្យប្រហារជីវិតនៃបង្គួយនោះបង់ៗ

ឯព្រះមហាសថបណ្ឌិតពោធិសត្វ ក៏ក្រាបទូលសូមជីវិតបង្គួយ ដោយជាសត្វតិរច្ឆានតូចពុំដឹងអ្វីមិនគប្បីនឹងទៅពីឃាដវ៉ា ហើយពោធិសត្វរកហេតុ ដែលនាំឲ្យបង្គួយកោងមិនចុះមកវន្ទាស្តេច ដូចថ្ងៃមុនៗ បានហៅនាយពិសេសមកសួរការ នាយពិសេសទូលថា បានយកមាសមួយពែក្តាម មកបោះចងកបង្គួយដោយរកទិញសាច់ឲ្យវ៉ាស៊ីមិនបានៗ

ព្រះពោធិសត្វជ្រាបហេតុដូច្នោះក៏សំដែងទោសមាសប្រាក់នោះថា ជាគ្រឿងនាំចិត្តសត្វនឹងមនុស្សឲ្យស្រវឹង កាន់អស្មិមានះឡើងចាងមានប្រការផ្សេងៗញុំាំងព្រះហឫទ័យនៃព្រះបាទវិទេហរាស្ត្រ ឲ្យរសាយព្រះក្រោធខឹងបង្គួយនោះឯងៗ ឯព្រះបាទវិទេហរាស្ត្រ ស្តេចក៏ឲ្យអមាត្យយកបង្គួយនោះទៅ



លែងចោលព្វដ៏ទៃទីព្រៃក្រៅ ពុំប្រោសប្រាណចិញ្ចឹមបង្គួយនោះតទៅទៀតឡើយៗ

រឿងនិទាននេះ មានសេចក្តីពិស្តារនៅក្នុងគម្ពីរទសជាតក៏ឯណោះ អញ្ជើញប្រាជ្ញទៅមើលយកចុះឯក្នុងតំរានេះបានទាញយកមកសំដែងដោយសង្ខេបឲ្យឃើញបែបអ្នកឥតពូជឥតសន្តានល្អ បានយសសក្តិហើយ រក្សាយសសក្តិនោះទុកយូរមិនបានត្រឡប់ជាធ្លាក់យសនោះវិញ ដូចបង្គួយរក្សាមាសមួយពែក្តាមមិនបាននោះឯង គួរចូលចិត្តចុះៗ

បង់អើយបង្គួយ បានមាសតូចមួយ កើតចិត្តឡើងចាង ចើងវាយកំពស់ កាន់យសក្អេងក្អាង ឃើញស្តេចមកខាង មិនចុះវន្ទាៗ អាងមាសចងក អំនួតអួតត បវមរាជា បានក្តីធ្លាក់ថ្លស់ ចាកយសសក្តា ត្រូវព្រះអាជ្ញា បណ្តេញចាកទីៗ

**ចប់តំរាមនុស្សផ្លូ ផ្ទឹមគួនឹងអ្នកធំជាគតិទី ៦០។**

## រឿងនាយព្រានព្រៃចាប់សត្វសារិកា

មាននាយព្រានព្រៃម្នាក់ទៅចាប់សត្វសាលិកា១ ក្ងោ១ កុក១ បានមកបង្ហាត់ក្នុងការល្បែងគឺសាលិកា បង្ហាត់ឲ្យចេះនិយាយស្តីជាភាសាមនុស្សឃើងបានគ្រប់ប្រការ ឯក្ងោកនឹងកុកបង្ហាត់ឲ្យ

ចេះទេរាំ ប្រើលំនាំទៅបានផ្សេងៗ ។ នាយព្រានបង្ហាត់សត្វទាំងបី បានចេះស្ទាត់ហើយ ទើបនាំយកទៅថ្វាយព្រះបរមរាជា នាព្រះរាជវាំងដើម្បីយសសក្តិនិងប្រាក់រង្វាន់តាមភាពជាតិព្រានព្រៃ ។ ព្រះបរមរាជា ទ្រង់ត្រាស់សួរថា សត្វទាំងបីនេះតើចេះអ្វីខ្លះនាយព្រានក្រាបទូលថា សត្វសាលិកានេះចេះនិយាយភាសាមនុស្សបាន ទូលហើយក៏ប្រើសាលិកាឲ្យនិយាយសាលិកាក៏សំដែងវិជ្ជាដែលខ្លួនចេះ គឺពោលពាក្យផ្សេងៗ ជាភាសាមនុស្សស្រេចហើយនាយព្រានប្រើក្ងោកឲ្យរាំថ្វាយ ក្ងោករាំទេកាប់កែ តាមចំណេះដែលខ្លួនចេះនោះបានផ្សេងៗ ព្រះបរមរាជាក៏សព្វព្រះទ័យនឹងសត្វទាំងពីរ ទើបទ្រង់ឲ្យអាមាត្យចាប់យកទៅដាក់ទ្រុងទុកជារបស់ព្រះរាជាទ្រព្យហ្លួង ។

នាយព្រានព្រៃក៏នាំកុកចេញមក ហើយប្រើកុកនោះឲ្យរាំថ្វាយព្រះបរមរាជាទៀត ឯកុកជាសត្វមានប្រាជ្ញា ស្គាល់កាលគួរកាលមិនគួរ គិតថា សត្វសាលិកាសត្វក្ងោកគេបានសំដែងចំណេះថ្វាយស្តេចៗសព្វព្រះទ័យ ទ្រង់ឲ្យដាក់ទ្រុងទុកជាព្រះរាជទ្រព្យហើយ ប្រសិនបើអញសំដែងចំណេះឡើង គង់ស្តេចនឹងឲ្យដាក់ទ្រុងទុកដូចគេ ធម្មតាការជាប់ទ្រុងនេះនឹងរកក្តីសុខឯណាមាន



មានតែក្តីទុក្ខក្តីរំខានជាប្រាកដបើដូច្នេះ កាលនេះមិនគួរនឹងសំដែងវិជ្ជាដែលចេះនោះទេ ត្រូវធ្វើល្ងង់វិញទើបរួច ខ្លួនគិតហើយកុកនោះពុំរាំឡើយ ធ្វើតែក្រកទៅក្រកមកៗប៉ុណ្ណោះ ឯងនាយព្រានប្រើឲ្យធ្វើដូចម្តេចៗ កុកក៏មិនធ្វើតាមចេះតែក្រកទៅក្រកមកដូច្នោះឯង ។ ឯព្រះបរមរាជាយល់កិរិយាកុកមិនចេះអ្វីដូច្នោះ ក៏ទ្រង់ត្រាស់ឲ្យនាយព្រានព្រៃស្រាយលែង នាយព្រានក៏លែងកុកនោះតាមព្រះបន្ទូលហោង ។

ឯកុកបានរួចចេញចាកដៃនៃនាយព្រានហើយក៏ហើរឡើងលើអាកាស ហើយបញ្ចេញឧទានវាចាថា "សត្វសាលិកានិងក្ងោកគេចេះប្រាជ្ញព្រោកញាំងមនុស្សលោកឲ្យត្រេកចិត្តបាន ធ្វើប្រាណឲ្យជាប់ទ្រុង មានសភាពយ៉ាងនេះ, អើថាហើយល្អហើយចៅទាំងពីរ, តែយើងយល់ថាការជាប់ទ្រុងគេនោះជាទីនាំមកនូវក្តីទុក្ខរំខាន បានជាយើងមិនសំដែងវិជ្ជាដែលចេះនោះ ស៊ូមាយាធ្វើល្ងង់ខ្លៅ ដើម្បីឲ្យគេស្អប់គេលែងចោលបង់ នឹងបានទៅជួបជុំវង្សញាតិសន្តានដែលព្រាត់ប្រាសមកនោះ សាលិកានឹងក្ងោកឯងចេះចំណេះព័ន្ធកឯងយ៉ាងនេះ ហៅថាចេះរបេះក្បាច់ហៅថាចំណេះជិះកឯងហើយ, នែសកុណបក្សីទាំងពីរអ្នកឯងមិន

ដឹងកាលគួរសំដែងចំណេះទៅសំដែងក្នុងកាលមិនគួរសំដែងបាន ជាអ្នកឯងជាប់ក្នុងទ្រុងទៅណាមិនរួចយ៉ាងនេះ" កុកនោះពោលពាក្យដូច្នោះហើយក៏ហើរទៅកាន់ទីតាមចិត្តប្រាថ្នាហោង ។

រឿងនេះបានគតិដល់បុគ្គលអ្នកចេះសំដែងចំណេះក្នុងកាលមិនគួរថ្លែង នាំឲ្យព័ន្ធកឯងវិញ ដូចយ៉ាងអ្នកខ្លះបានឃើញបានឮអ្វី ហើយនាំមកសំដែងក្នុងកាលប្រជុំអ្នកធំ ដល់អ្នកធំគេត្រូវការឡើង ក៏ប្រើឯងឲ្យទៅធ្វើការនោះ ឬការនោះជាការកំបាំងខ្លួនទៅថ្លែង គេប្រកាន់ខ្លួនជាប់ថា ខ្លួនបានដឹងបានឮ ហើយគេហៅយកខ្លួនទៅសំដែង ការនោះឯងត្រូវពាក់ព័ន្ធមកលើខ្លួនវិញយ៉ាងនេះក៏មាន គតិអស់នេះ នៅមានច្រើនតទៅទៀត អញ្ជើញប្រាជ្ញពិចារណាទៅទៀតចុះ ។

កុកអើយនាងកុក ត្រិះយល់ក្តីសុខ ក្តីទុក្ខសម្កាយ កាលខុសដំណែង មិនថ្លែងអភិប្រាយ ក្លែងធ្វើខ្លៅក្លាយ ញុាំងកាយរួចបាន ។ វិជ្ជាចំណេះ គួរធ្វើខ្លៅក្លាយ ញុាំងកាយរួចបាន ។ វិជ្ជាចំណេះ គួរចាគួរចេះ គួរដឹងប្រមាណ គួរពោលល្មមពោល គួរខានល្មខាន កុំអាងតែប្រាណ ប្រាជ្ញព្រោកព្រើលថ្លែង ។ នេះហើយចេះចប់ ចេះមិនប្រសប់ ក្នុងកាលសំដែង ចេះនោះប្រែជាន់ ចេះព័ន្ធកឯង ចេះកាលមិនថ្លែង ចេះឯងមិនថ្លៃ ។



**ចប់តម្រាពោលវិជ្ជាខុសកាលជាគតិទី ៦១។**

## រឿងចៅសញ្ជីវមាណពប្រោះខ្លា

មានចៅមាណពម្នាក់ឈ្មោះ សញ្ជីវមាណពបានទៅរៀនសិល្បវិទ្យាគមក្នុងសំណាក់អាចារ្យទិសាបាមោក្ខព្រាហ្មណ៍ រៀនបានចេះវិជ្ជាផ្សេងៗ ។

ថ្ងៃមួយ ចៅមាណពនាំបណ្តាភឿនសិស្សដូចគ្នា៤-៥ នាក់លាអាចារ្យទៅលេងព្រៃ លុះទៅដល់ព្រៃស្រោង១ ឃើញសាកសពខ្លាទើបនឹងស្លាប់ថ្មីៗ ចៅមាណពចង់ល្បងសិល្បសាស្ត្រខ្លួនទើបនិយាយប្រាប់ភឿនថា យើងនឹងសេកមន្តប្រោះខ្លានេះឲ្យរស់វិញបាន អ្នកទាំងឡាយចាំមើលចំណេះយើងចុះ ។ ឯពួកភឿនទាំងឡាយឮដូច្នោះ ក៏ឃាត់រាល់គ្នាថា ខ្លានេះជាសត្វស៊ីសាច់ មិនត្រូវប្រោះឲ្យវារស់ឡើងទេតែរស់ឡើងហើយវាមិនដឹងគុណនរណាទេ វានឹងខាំអ្នកនោះវិញ ហេតុដូច្នោះកុំទៅប្រោះវាឡើយ បើអ្នកឯងមិនស្តាប់ពាក្យយើងឃាត់នេះយើងនឹងនាំគ្នារត់ឡើងដើមឈើ ចោលអ្នកឯងក្នុងកាលឥឡូវនេះឯងហើយ ។

ឯចោមាណពក៏ថា បើអ្នកឯងខ្លាចខ្លាហើយចង់រត់ចោលយើងក៏តាមចិត្តចុះ យើងមិនស្តាប់ពាក្យអ្នកឯងឃាត់នោះទេយើងនឹងប្រោះខ្លានេះឥឡូវនេះឯងថាហើយក៏តាំងវាយមន្ត សូត្រប្រោះសត្វខ្លានោះឯង ឯពួកភឿនទាំងឡាយ កាលបើឃាត់ចៅមាណពនោះមិនស្តាប់ហើយ ក៏នាំគ្នាឡើងដើមឈើទាំងអស់គ្នាហោងៗ

ឯខ្លានោះ លុះត្រូវទេវទមន្តចៅសញ្ជីវមាណពហើយ ក៏មានជីវិតរស់ឡើង ហើយឃើញមាណពនោះនៅជិតខ្លួន ក៏ស្ទុះទៅទះកាច់កឱនត្របាក់ស៊ីមួយរំពេច ចៅសញ្ជីវមាណព ក៏ដល់នូវកាលកិរិយាក្ស័យនឹងដៃខ្លានោះហោងៗ

ឯបណ្តាភឿនទាំងឡាយ កាលបើឃើញខ្លាវាខាំចៅសញ្ជីវមាណពហើយក៏ភិតភ័យ ទើបនាំគ្នាចុះចាកព្រឹក្សា រត់ទៅស្រុកទៅប្រាប់អាចារ្យទិសាបាមោក្ខតាមរឿងខ្លាវាខាំចៅសញ្ជីវមាណពនោះហោងៗ

រឿងនេះ បានគតិដល់បុគ្គលអ្នកមិនស្គាល់អំពើពាល ទៅធ្វើគុណនឹងពាល ពាលនោះមិនដឹងគុណនរណាទេ តែវាបានឱកាសកាលណាហើយ វាក៏យាយីវិញក្នុងកាលនោះ ប្រាជ្ញគួរគិតទៅចុះធម្មតាសត្វស៊ីសាច់ ដូចយ៉ាងខ្លាយ៉ាងក្រពើនោះ ជាតិមនុស្សយើង



មិនត្រូវធ្វើគុណនឹងវាឡើយ មួយទៀតអ្នកមានវិជ្ជាមិនត្រូវទៅសំដែងវិជ្ជានោះក្នុងកាលមិនគួរសំដែងដូចយ៉ាងចៅសញ្ជីវមាណពទៅប្រោះខ្លានោះឯង ខ្លាវាខាំវិញហោងៗ

រឿងនេះ មានសេចក្តីពិស្តារក្នុងគម្ពីរមង្គលត្ថទីបនីឯណោះ អញ្ជើញទៅមើលចុះៗ

មាអើយមាណព ចេះសិល្បសាស្ត្រដប់ ជីវិតខ្លាបាន ធម្មតាខ្លាខ្លៅ ចិត្តខ្លៅសាមាន្យ មិនដឹងគេមាន គុណលើអាត្មាៗ ជាសប្បុរស ទៅជប់ទៅប្រោះ ឲ្យរស់រូបា ត្រឡប់ក្រញាំ ខាំក្បាលវិញណា នេះព្រោះអាត្មា មិនស្គាល់ពិសពាល ៗ

**ចប់តំរាសំដែងវិជ្ជាជួយអសប្បុរស ជាគតិទី ៦២។**

## រឿងបុរសម្នាក់ឈ្មោះចៅស្លាយធាតុ

មានបុរសកំឡោះម្នាក់ ឈ្មោះចៅស្លាយធាតុនៅក្នុងជនបទមួយ មានចិត្តស្រឡាយនាងកុលធីតាម្នាក់ ចង់បានជាភរិយាៗ នាងកុលធីតានោះ មានរូបសោភា ជាទីគាប់ចិត្តនៃក្មេងកំឡោះទាំងឡាយ សឹងចង់បាននាងធីតានោះគ្រប់ៗគ្នា លុះនៅយូរមកនាងកុលធីតានោះមានជម្ងឺឈឺស្គមលឿង ក៏ធ្វើកាលកិរិយាក្ស័យបង់ៗ ពួកញាតិនឹងមាតាបិតា នាំយកសពនាងនោះទៅដុតនៅ

ទីប៉ាឆា តាមទំនៀមវង្សព្រាហ្មណ៍ ។

កាលនោះមានចៅកំឡោះម្នាក់ ឈ្មោះចៅសមរណមាណព មានចិត្តស្ម័គ្រប្រតិព័ទ្ធ នឹងរូបនាងធីតានោះក្រៃពេកណាស់ គ្រាន់តែបានដឹងថា នាងកុលធីតានោះស្លាប់ហើយ ក៏មានសេចក្ដីសោកស្ដាយអាឡោះអាល័យក្រៃពេក ទើបចាក់ចែងតែងអាត្មាទៅកាន់ព្រៃប៉ាឆានាវេលានោះពួកញាតិទាំងឡាយ ដឹកល់សពនៅលើជើងថ្ករ ពុំទាន់បូជាភ្លើង ហើយនាំគ្នាទៅអាស្រ័យបាយឯផ្ទះទាំងអស់គ្នា ពុំមាននរណាមួយ នៅរក្សាសពនោះឡើយ ។ ឯចៅសមរណមាណពបានឃើញក្ដារមឈូស នាងធីតានៅលើជើងថ្ករ ឥតមាននរណានៅកំដរដូច្នោះ ក៏លបបើកក្របក្លាសហើយ ចូលទៅដេកឱបសពនាងធីតានៅក្នុងក្ដារដោយចិត្តស្នេហាស៊ូស្លាប់ជាមួយនឹងនាងនោះឯង ។

ឯពួកញាតិទាំងឡាយ កាលបើរួចកិច្ចបាយហើយគេក៏នាំគ្នាមកដុតសពនាងធីតានោះតាមប្រពៃណី ។ សពទាំងពីរក៏លាយឆ្អិនចូលជាមួយគ្នាហោង ។

ថ្លែងឯចៅស្ពាយធាតុ កាលបានដឹងថានាងធីតាធ្វើកាលកិរិយាស្លាប់ហើយ ក៏មានសេចក្ដីសោកស្ដាយ ដោយក្ដីស្នេហាខ្លាំងក្រៃ



ទើបចេញចាកគេហស្ថានទៅកាន់ប៉ាឆា តាំងសោកអាល័យអង្គុយយំនៅទីដុតខ្មោចនោះ ហើយក៏រើសធាតុដាក់ថង់ដោយគិតថា នឹងយកឆ្អឹងនាងធីតានោះ ទៅឲ្យព្រះមហាឥសីលោកប្រោះផុបឲ្យ ហើយយកធ្វើជាភរិយា មិនដឹងថានាងធីតាមានគេដេកស្លាប់ជាមួយ ឆ្អឹងធាតុនៅលាយជាមួយគ្នាឡើយ ។ ចៅស្ពាយធាតុក៏តាំងប្រមូលធាតុទាំងអស់ដាក់ថង់ ហើយស្ពាយដើរទៅកាន់ព្រៃហិមពាន្ត លុះទៅដល់ទីអាស្រមមហាឥសីក៏ធ្វើអាការទោមនស្សតូចចិត្ត ចូលទៅក្រាបសំពះព្រះឥសីថ្លែងសេចក្ដីថា "បពិត្រព្រះករុនាម្ចាស់! ខ្ញុំព្រះករិណានេះជាមនុស្សកំព្រា ឥឡូវភរិយាស្លាប់ចោលបង់ ព្រះគុណអើយ! នាងភរិយានេះជាទីស្រឡាញ់ពេញចិត្តខ្ញុំព្រះករុណាក្រៃពេកណាស់ បានជាខ្ញុំស្ពាយធាតុយកមកដល់ព្រះករុណា សូមព្រះករុណាមេត្តាប្រោសប្រោះជីវិតនាងឲ្យរស់ដូចដើមវិញ ខ្ញុំព្រះករុណា នឹងបាននៅជាមួយគ្នាតទៅ" ។ ឯព្រះមហាមុនីបានស្ដាប់ពាក្យចៅស្ពាយធាតុដូច្នោះ ក៏អាណិតមេត្តាទើបទទួលថា "អើ ចៅចាំយើងប្រោះឲ្យ" ថា ហើយក៏តាំងសមាធិបរិកម្មព្រះវេទប្រោះធាតុនោះ ។ ឯធាតុនាងធីតានឹងធាតុចៅសមរណមាណព កាលបើត្រូវឫទ្ធិព្រះវេទ

វិសេសហើយក៏កើតឡើងជារូបប្រាកដទាំងពីរ ចំពោះនៅមុខ
ព្រះមហាឥសីៗ បានយល់រូបស្ត្រីនិងបុរសដូច្នោះ ក៏សួរទៅចៅ
ស្លាយធាតុថា "អើ ចៅអើយ កាលដើមចៅប្រាប់យើងថាប្រពន្ធ
ជាទីគាប់ចិត្តស្លូតត្រង់នឹងខ្លួន ស្លាប់ទៅតែម្នាក់ឯងទេឥឡូវនេះ
ម្ដេចក៏ឃើញរូបដល់ទៅពីរយ៉ាងនេះ រូបប្រុសនេះគេជាប្ដី
នាងនេះទេដឹង ចៅឯងទៅរើសយកធាតុគេផ្ដាសមកដូច្នេះ
តើយើងនឹងលើកនាងធីតាឲ្យទៅចៅឯងម្ដេចបាន"ៗ ចៅស្លាយ
ធាតុបែរទៅឃើញរូបប្រុសនៅរួមនឹងនាងធីតាដូច្នោះ ក៏អន់
ចិត្តគិតថាការនេះមិនសំរេចដល់ខ្លួនហើយ តែមិនសុខចិត្តទើប
ពិតពុទ្ធដីកាថា "ករុណាម្ចាស់ នាងនេះរស់ឡើងបានក៏ព្រោះខ្ញុំ
ករុណាខំឧស្សាហ៍ ព្យាយាមនាំយកធាតុវាមកដល់ព្រះករុណា
ហើយបាននិមន្តព្រះករុណាឲ្យប្រោះដូច្នេះត្រូវព្រះករុណាប្រ
ទានឲ្យខ្ញុំហោង"ៗ

ព្រះមហាឥសីក៏តបថា "ការនេះនឹងលើកឲ្យដល់ចៅឯងពុំទាន់
បាន ព្រោះមានប្រុសពីរនាក់យ៉ាងនេះតោងសួរចិត្តស្រីកណ្ដាល
សិន ជាចិត្តនាងតើព្រមស្ម័គ្រទៅនឹងប្រុសណា", ថាហើយព្រះសី
លាក៏សួរទៅនាងធីតានោះថា "អើនាង ចៅនេះគ្នាខំខ្មីឃ្មាត



ស្លាយធាតុនាងឯងយកមកឲ្យប្រោះ ដើម្បីនឹងយកជាភរិយា
ឥឡូវនាងឯងរស់ហើយតែមានប្រុស កើតរួមជាមួយផង ដូច្នេះ
តើនាងឯង នឹងទទួលយកប្រុសណាជាប្ដីចូរថាទៅមើលយើង
នឹងផ្សំផ្គុំឲ្យ"ៗ

ឯនាងធីតាក៏ពិតពុទ្ធដីកាថា "ខ្ញុំព្រះករុណាយល់ឃើញថាអ្នក
បងស្លាយធាតុនេះ គាត់មានគុណវិសេសទុកស្មើបិតាបង្កើតខ្លួន
ហើយ តែអ្នកបងដែលស្លាប់ជាមួយរស់ជាមួយនេះ ឃើញចិត្ត
វិសេសណាស់ ក្នុងលោកនេះរកចិត្តប្រុសយ៉ាងនេះពុំមាន ហេតុ
នេះត្រូវព្រះករុណាផ្សំផ្គុំខ្ញុំនឹងអ្នកបង សមរណមាណពនេះចុះ
ឯអ្នកបងស្លាយធាតុនោះ ខ្ញុំទុកគាត់ជាបងធំឬជាបងបង្កើត
ទៅចុះ ព្រោះគាត់មានគុណបាននាំយកធាតុខ្ញុំមកឲ្យព្រះករុណា
ប្រោះរស់រួចបាន ដោយសភាពយ៉ាងនេះ"ៗ ឯព្រះឥសីបាន
ស្ដាប់សំដីនាងធីតាថាដូច្នោះ ក៏យល់ត្រឹមត្រូវពិតមែន ទើបផ្សំ
នាងធីតានោះ ឲ្យជាភរិយានៃចៅសមរណមាណព តាំងចៅស្លា
យធាតុឲ្យជាបងធំ ស្រេចហើយក៏ឲ្យដំណើរអ្នកទាំង៣ វិល
ទៅស្រុកវិញហោងៗ

រឿងនេះ បានគតិដល់បុគ្គលយល់តែផ្លូវបានលាភចំណែក

មួយ មិនដឹងជាលាភនោះមានអាការយ៉ាងណាៗ ប្រាជ្ញមានបញ្ញាគួរគិតទៅទៀតចុះ ៕

ជនអើយជនជាតិ ជនខំខ្មីឃ្មាត ស្លាយធាតុយាត្រា ទៅរកតាបស ឲ្យប្រោះកញ្ញា ដោយចិត្តគិតថា បានខ្លួនជាប្តី ៕ មិនដឹងមារយាទ ឆ្អឹងប្រុសលាយជាតិ នឹងធាតុប្អូនស្រី ស្រាច់តែលោកប្រោះ រូបរស់ជាប្តី ឃើញរូបប្អូនស្រី មានប្តីនៅហើយ ៕ ស្អុនអើយស្អុនស្អាត់ ស្អុនសោកវិបត្តិ ខានបានរួមខ្នើយ មិនដឹងកលស្នៀត កន្លៀតប្អូនឡើយ បានគូកៀកកើយ រួមរស់ទេវី ៕ បង់អើយបង់ជាតិ បំណាប់ស្លាយធាតុ មកដល់យោគី ឥឡូវបានគេ នឿយតែឥន្ទ្រីយ សាច់មិនបានស៊ី យកឆ្អឹងព្យួរក ៕

**ចប់តម្រាសាច់មិនបានស៊ីយកឆ្អឹងព្យួរក ជាគតិទី ៦៣។**

## រឿងខ្មោចចូលដប

មានខ្មោចប្រុសមួយ អាស្រ័យនៅក្នុងទីមួយបានឃើញប្រពន្ធអ្នកចំការម្នាក់ កើតក្តួចចិត្តប្រតិព័ទ្ធស្រឡាញ់នាងនោះ លុះពេលណាប្តីនាងមិននៅ អាខ្មោចនោះវាប្លែងកាយនិម្មិតជារូបប្តីនាង នៅដេកនឹងនាងនោះៗ ក៏សំគាល់ថាជាប្តីអាត្មា មិនដឹងជាខ្មោចវាប្លែងឡើយ ព្រោះដូចគ្នាណាស់ ៕



ឯខ្មោចនោះតែបានឱកាស គឺអ្នកចំការមិននៅហើយវាក៏តែងប្លែងកាយជារូបប្តីមកដេកនៅនឹងនាងនោះជារឿយៗ រាល់ៗកាលហោង លុះនៅយូរបន្តិចមកចៅប្តីនោះទៅព្រៃ ឯអាខ្មោចវាប្លែងទៅដេកនឹងនាងនៅក្នុងផ្ទះដល់ពេលចៅប្តីមកផ្ទះ ក៏គ្មានឃើញរូបអាខ្មោចដូចរូបខ្លួនដេកនៅនឹងប្រពន្ធខ្លួនដូច្នោះ ក៏ខឹងមហិមា ស្ទុះទៅចាប់អាខ្មោចៗក៏ឈ្លោះតបថា "យើងជាប្តីនាងនេះ ផ្ទះនេះគឺជាផ្ទះរបស់យើង ហេតុអ្វីចៅមកចាប់យើងជាម្ចាស់ផ្ទះវិញ ចៅឯងមកពីទីស្ថានណាមិនដឹងយើងជាប្តីនាងនេះទេឬ? ៕ ឯចៅប្តីក៏ឈ្លោះតបថានេះជាផ្ទះរបស់យើង "នាងនេះសោត ក៏ជាប្រពន្ធយើងហេតុអ្វីចៅមកថារបស់ខ្លួនដូច្នេះ" ៕

ខ្មោចនឹងមនុស្ស ក៏ឈ្លោះគ្នាដណ្តើមប្រពន្ធទៅវិញទៅមកជាកោសាហលឡើង ឯនាងប្រពន្ធ ក៏មិនដឹងរូបប្រុសណាជាប្តីខ្លួនព្រោះរូបរាងដូចគ្នាសុទ្ធគ្នាណាស់ នឹងអារកាត់ថារូបណាជាប្តីខ្លួនពុំបាន ព្រោះចៅខ្មោចនឹងមនុស្សកើតជាអធិករណ៍នឹងគ្នា ទើបនាំគ្នាទៅកាន់សាលាវិនិច្ឆ័យ(១) ដល់ហើយក៏នាំគ្នាចូលប្តឹងតាមរឿងនោះ ៕

(១) សាលាវិនិច្ឆ័យក្នុងរឿងនេះ គឺសាលាសម្រាប់ជំរះក្តី មិនមែនជាសាលាវិនិច្ឆ័យដែលជាសាលាជាន់ខ្ពស់បំផុតដូចសព្វថ្ងៃនេះទេ។

ឯចៅក្រមខាងជាន់ក្រោម ពុំអាចនឹងកាត់ក្ដីនោះបាន ព្រោះសាក្សីស្រីកណ្ដាលនោះឲ្យការមិនផ្ទុះទៅបាន ទើបនោះរឿងក្ដីនោះឡើងប្ដឹងដល់លោកអ្នកធំជាន់ខ្ពស់ គឺលោកអ្នកប្រាជ្ញៗក៏ឲ្យហៅចៅទាំងពីរចូលទៅជិត ហើយលេកពិនិត្យមើលរូបមើលមុខមាត់ចៅខ្មោចនោះ ក៏យល់ស្គាល់ជាមនុស្សជាខ្មោចបានប្រាកដ ព្រោះភ្នែកខ្មោច ភ្នែកយក្សខុសគ្នានឹងភ្នែកមនុស្សយើងនេះ គឺភ្នែកខ្មោចយក្សឥតស្រមោលកូនក្រមុំ ហើយច្រើនក្រហមច្រើនរឹង ហេតុនោះទើបអ្នកប្រាជ្ញលោកស្គាល់បាន តែលោកនឹងកាត់ថាអានេះជាខ្មោចប្លែងរូបជាមនុស្សដូច្នេះទៅក៏ពុំប្រាកដដល់ភ្នែកអ្នកឯទៀតៗឡើយ ទើបលោកយកដបស្រា១មកតាំងនៅលើតុ ហើយវិនិច្ឆ័យឡើយថា "ហៃចៅទាំងពីរដែលវិវាទគ្នា អើគ្រានេះយើងនឹងវិនិច្ឆ័យដោយយុត្តិធម៌ឲ្យ គឺយើងតាំងពិសោធនឹងដបនេះថាបើរូបណាក្លាហានអាចចូលក្នុងដបនេះបាន រូបនោះហើយជាប្ដីនាងនេះមែន យើងក៏នឹងប្រគល់នាងនេះឲ្យ ជាប្រពន្ធពិត ថាបើរូបណាចូលដបនេះពុំបានទេ អើយើងទុករូបនោះថាជាពុំមែនប្ដីនាង ពុំមែនជាម្ចាស់របស់ឡើយ"។



ឯចៅមនុស្សនោះ បានឮលោកអ្នកប្រាជ្ញដាក់ទុកដូច្នោះក៏តក់ស្លុតភិតភ័យ ដោយគិតថាខ្លួនជាមនុស្សនឹងចូលដបស្រាតូចមួយនេះឯណាបាន ក្ដីចាញ់នោះចំពោះនឹងបានដល់ខ្លួនប្រាកដហើយ ម្ល៉ោះហើយក៏ឈរសំពះព្រះនៅហោង។

ឯអាខ្មោច លុះឮអ្នកប្រាជ្ញតាំងឲ្យចូលដបស្រាដូច្នោះ ក៏ត្រេអរក្នុងចិត្តដោយគិតថាខ្លួនជាខ្មោចឥតឆ្អឹងឥតសាច់សំរេចដោយឫទ្ធិនិម្មិតជាខ្យល់បានទើប ទទួលចូលដបកាលនឹងចូលនោះចៅខ្មោចឡើងទៅលើតុ ហើយបង្អោនក្បាលសម្របរូបតូចចូលទៅក្នុងដបនោះបានហោង។

ឯអ្នកប្រាជ្ញ កាលបើយល់ខ្មោចចូលក្នុងដបដូច្នោះក៏យកឆ្នុកចុកមាត់ដបនោះជាប់ ហើយលើកឡើងប្រកាសប្រាប់អស់មហាជនទាំងឡាយថា អ្នកទាំងឡាយចូរដឹងថាអានេះជាខ្មោច វាប្លែងខ្លួនជាមនុស្សមកធ្វើអំពើបទោរកម្មយ៉ាងនេះយើងពិសោធនេះ ដើម្បីឲ្យដឹងថាអាណាជាប្ដីនាងនេះមែនៗ ក៏ធម្មតាមនុស្សយើងតើឯណានឹងចូលដបស្រានេះបាន មានតែខ្មោចទើបវាចូលបាន ឥឡូវនេះយើងរកក្ដីពិតឃើញហើយ នាងនេះត្រូវប្រគល់ឲ្យទៅចៅដើមចោទនោះចុះ ឯអាខ្មោចនេះទុកវានៅ

ស្រុកនេះពុំបានទេ ព្រោះវាធ្វើអំពើលាមកមានសភាពយ៉ាងនេះថាហើយក៏ប្រើអ្នកបំរើឲ្យនាំយកដបខ្មោច នោះទៅបោះបោលព្វដីទីអន្លង់ទឹកជ្រៅ ៗ អ្នកបំរើក៏នាំយកដបខ្មោចនោះទៅបោះបោលក្នុងទឹកហូរតាមពាក្យប្រាជ្ញនោះហោង ៗ

ឯអាខ្មោចក៏វិនាសខ្លួនអស់ក្បួនតែត្រឹមនេះ ៗ

រឿងនេះ បានគតិដល់បុគ្គលអ្នកកាន់ទូវិជ្ជាការគឺ ចេះធ្មប់ចេះថ្នាំបំពុលគេ ឬចេះក្បួនអ្នកលេង ដើរលបចាក់កាប់ក្បាលគេជាដើម ហើយមានលោកអ្នកធំ លោកត្រូវការចង់រកក្តីកំណាចនោះ ខ្លួនមិនដឹងក្តីអន្តរាយក្រោយ ក៏ទៅសំដែងទុវិជ្ជានោះប្រាប់លោកអ្នកធំដើម្បីយករង្វាន់ ការនោះជាផ្លូវឲ្យលោកអ្នកធំចាប់ខ្លួនធ្វើខ្លួនឲ្យវិនាស ដោយអាជ្ញាវិញបាន ដូចអាខ្មោចក្នុងដបនោះឯង ប្រាជ្ញគួរគិតទៅទៀតចុះ ៗ

ខ្មោចអើយខ្មោចខ្មាំង ទទួលប្រណាំង តាំងភ្នាល់ចូលដប ទើបស្ទុះឱនសីរ ដែពីរសម្រប សម្រាលខ្លួនខ្លប ចូលដបបានងាយ ៗ បង់ឈ្មោះយកស្រី មិនដឹងកលក្តី វិនាសរូបកាយ ត្រូវចុកផ្ទុកជិត អស់ឫទ្ធិនឹងប្រាយ ដូចកូនទន្សាយ កាយហោងក្នុងដប ៗ



ចប់តំរាខ្មោចក្នុងដបជាគតិ ទី ៦៤។

ចប់ភាគទី ៥ តែប៉ុណ្ណោះ។

---